# រស់នៅជាមួយព្រះ ស្វែងរកព្រះ ហើយពឹងលើព្រះចុះ

## ព្រះគម្ពីរ របក្សត្រទី២ ១៤-១៦

ស្តេចអេសាជាគំរូល្អសម្រាប់អ្នកជឿលើព្រះយេស៊ូវ ប៉ុន្តែនៅពេលដែលព្រះបាទអេសាមានព្រះជន្មចាស់ ទ្រង់ទៅជាគំរូមិនល្អទៅវិញ។ ក្នុងរាជ្យរបស់ព្រះបាទអេសា ជំនឿរបស់របស់ព្រះអង្គទៅលើព្រះយេហូវ៉ាមានការសាកល្បងលមើល២ដង។ យើងនឹងរៀនអំពីពេលវេលាទាំងពីរដែលអេសាបានទទួលការល្បងលនោះ។

បន្ទាប់ពីរាជ្យរបស់ស្តេចដាវីឌ មានរាជ្យរបស់ព្រះបាទសាឡូម៉ូន (មិនស្មោះត្រង់នឹងព្រះយេហូវ៉ា) ព្រះបាទរេហូបោម (អាក្រក់ អ៊ីស្រាអែលបានបែកជាប្រទេសពីរ) ព្រះបាទអ័ប៊ីយ៉ា (អាក្រក់) និងព្រះបាទអេសា។ ព្រះអង្គបានរាប់ស្តេចអេសាជាស្តេចល្អ។

**<u>អាន របក្សត្រ ទី២ ១៤:២-៥ និងពន្យល់</u>**

**«ឯព្រះបាទអេសាបានប្រព្រឹត្តសេចក្តីដែលល្អ ហើយត្រឹមត្រូវនៅព្រះនេត្រព្រះយេហូវ៉ា ជាព្រះនៃទ្រង់។ (ខ២)»**

**<u>អាន របក្សត្រ ទី២ ១៤:៦-៨ និងពន្យល់</u>**

រាជ្យដំបូងរបស់ព្រះបាទអេសា មានតែព្រះពរនិងសេចក្តីស្រាកស្រាន្ត។ ពិសេធរបស់ស្តេចអេសាខុសគ្នាពីស្តេចអាក្រក់មុនផ្ងាយណាស់!

# ការសាកល្បងលមើលជំនឿរបស់ព្រះបាទអេសាជាលើកទី១

**អាន របក្សត្រ ទី២ ១៤:៩-១០ និងពន្យល់**

ក្នុងរាជ្យរបស់ព្រះបាទរេហូបោម ទ័ពពីទ្វីបអាហ្វ្រិកធ្លាប់ឡើងមកបំផ្លាញប្រទេសអ៊ីស្រអែល ឥឡូវពួកគេមកទៀតហើយ ពលទ័ពរបស់គេមានមួយលាននាក់។ តើព្រះបាទអេសានឹងឆ្លើយតបយ៉ាងដូចម្ដេច?

តើព្រះអង្គនឹងជួលពលទ័ពពីប្រទេសក្រៅឲ្យមកជួយសង្គ្រោះឬទេ? តើព្រះអង្គនឹងអង្វរប្រទេសផ្សេងៗដែលមានសម្ពន្ធភាពជាមួយឲ្យមកជួយចំបាំងឬទេ? ព្រះយេហូវ៉ាសព្វព្រះហឫទ័យឲ្យស្ដេចអ៊ីស្រាអែលពឹងលើទ្រង់តែប៉ុណ្ណោះ។ តើព្រះបាទអេសានឹងធ្វើអ្វី?

**អាន របក្សត្រ ទី២ ១៤:១១-១៣ និងពន្យល់**

**«ឱព្រះយេហូវ៉ាជាព្រះនៃយើងរាល់គ្នាអើយ សូមជួយយើងខ្ញុំផង ដ្បិតយើងខ្ញុំផ្អែកលើទ្រង់ជាទីពឹង (ខ១១)»**

ព្រះយេហូវ៉ាបានជួយសង្គ្រោះសាសន៍យូដាដូចដែលព្រះបានសន្យា ពីព្រោះព្រះបាទអេសាបានទុកចិត្តលើទ្រង់។

## ការអនុវត្តន៍តាមគំរូល្អរបស់ព្រះបាទអេសា

- នៅពេលដែលយើងខ្លាចយើងត្រូវស្វែងរកព្រះ ហើយពឹងលើទ្រង់ កុំពឹងលើប្រាជ្ញារបស់ខ្លួន ឬគំនិតរបស់អ្នកដទៃទេ។
- នៅពេលដែលយើងមានទុក្ខលំបាកណាមួយ យើងត្រូវធ្វើតាមព្រះហឫទ័យនៃព្រះ ហើយកុំសង្ស័យ។

**<u>អាន សុភាសិត ៣:៥-៦ និងពន្យល់</u>**

**«ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ។ ត្រូវទទួលស្គាល់ព្រះអង្គនៅគ្រប់ទាំងផ្លូវឯងចុះ ព្រះអង្គនឹងតម្រង់អស់ទាំងផ្លូវច្រករបស់ឯង។»**

**<u>អាន ទំនុកដំកើង ៥៦:៣ និងពន្យល់</u>**

**«ពេលទូលបង្គំភ័យខ្លាច ទូលបង្គំទុកចិត្តដល់ព្រះអង្គ។»**

ស្តេចអេសាបានប្រឡងជាប់ក្នុងការល្បងលមើលជំនឿរបស់ទ្រង់ជាលើទីមួយនេះ ទ្រង់បានជោគជ័យ។

# ព្រះមានបន្ទូលទៅកាន់ព្រះបាទអេសា តាមរយៈលោកអ័សារា

**<u>អាន របាក្សត្រ ទី២ ១៥:១-២ និងពន្យល់</u>**

**«កំពុងដែលអ្នករាល់គ្នានៅជាមួយព្រះយេហូវ៉ា ព្រះអង្គក៏គង់ជាមួយអ្នករាល់គ្នាដែរ បើអ្នករាល់គ្នាស្វែងរកព្រះអង្គ នោះនឹងរកឃើញពិត តែបើអ្នករាល់គ្នាបោះបង់ចោលព្រះអង្គវិញ ព្រះអង្គក៏នឹងបោះបង់ចោលអ្នករាល់គ្នាដែរ។»**

សំខាន់ណាស់ដែលព្រះបាទអេសា «***នៅជាមួយព្រះយេហូវ៉ា***»។ ទ្រង់ត្រូវនៅជាមួយព្រះយេហូវ៉ារហូត ពឹងលើព្រះរហូត ទ្រង់ត្រូវស្វែងរកព្រះយេហូវ៉ារហូត។ នៅពេលនេះ ព្រះអង្គព្រមានអេសា និងសាសន៍យូដាថា កុំធ្វើដូចប្រជាជនតំណមុនៗដែលវង់វែងពីព្រះ ហើយបានទទួលការវាយផ្ចាលនៃព្រះយេហូវ៉ានោះទេ។

*****ការជោគជ័យអតីតកាលមិនធានាការជោគជ័យនៅពេលអនាគត!*****

**<u>អាន របាក្សត្រ ទី២ ១៥:៧ និងពន្យល់</u>**

**«តែឯអ្នករាល់គ្នា ចូរខំប្រឹងឡើង កុំឲ្យដៃថយកម្លាំងឡើយ ព្រោះការដែលអ្នករាល់គ្នាធ្វើ នោះនឹងបានរង្វាន់»។**

យើងត្រូវតែជឿថា បើសិនជាយើងធ្វើតាមព្រះហឫទ័យព្រះ ទ្រង់នឹងនៅជាមួយយើង។ យើងត្រូវតែជឿថា បើយើងពឹងលើព្រះក្នុងគ្រាលំបាក ទ្រង់ពិតជានឹងរៀបចំផ្លូវឲ្យយើង។ មានរង្វាន់សម្រាប់អស់អ្នកណាដែលពឹងលើទ្រង់ ទោះបីជាទាន់ខឃើញរង្វាន់នោះក៏ដោយ។

# ការសាកល្បងលមើលជំនឿរបស់ព្រះបាទអេសាជាលើកទី២

*****ការជោគជ័យអតីតកាល់មិនធានាការជោគជ័យនៅពេលអនាគត!*****

បន្ទាប់ពីសាសន៍យូដាបានឈ្នះពលទ័ពមួយលាននាក់នោះ រហូតដល់ឆ្នាំទី៣៥ក្នុងរាជ្យរបស់ព្រះបាទអេសា សាសន៍យូដាគ្មានចម្បាំងទៀតទេ។ តែនៅពេលក្រោយមក ព្រះបាទបាសាសាសន៍អ៊ីស្រាអែល មកទាស់នឹងពួកយូដា ហើយវាយឈ្នះសាសន៍យូដា និងព្រះបាទអេសា។ នៅពេលនោះ ព្រះបាទអេសាមិនស្វែងរកព្រះយេហូវ៉ានៅពេលខ្លាចនោះទេ តែទ្រង់បានពឹងលើទ័ពពីប្រទេសក្រៅទៅវិញ។ អេសាបានប្រមូលប្រាក់ និងមាស ពីឃ្លាំងក្នុងព្រះវិហារផ្ញើទៅស្តេចស្រុកស៊ីរី។ ទ័ពពីស្រុកស៊ីរីដែលស្តេចអេសាបានជូលនោះបានជួយដេញទ័ពរបស់សាសន៍អ៊ីស្រាអែលមែន ប៉ុន្តែទង្វើរបស់ព្រះបាទអេសានោះមានផលវិបាកអាក្រក់។

# ព្រះមានបន្ទូលទៅកាន់ព្រះបាទអេសា តាមរយៈលោកហាណានី

**<u>អាន របក្សត្រ ទី២ ១៦:៧-៩ និងពន្យល់</u>**

**«ដ្បិតព្រះនេត្រនៃព្រះយេហូវ៉ាចេះតែទតច្រវាត់ នៅគ្រប់លើផែនដីទាំងមូល ដើម្បីសម្តែងព្រះចេស្តា ជួយដល់អស់អ្នកណាដែលមានចិត្តស្មោះត្រង់ចំពោះព្រះអង្គ ព្រះករុណាបានប្រព្រឹត្តបែបឆោតល្ងង់។ ដ្បិតពីនេះទៅមុខ នឹងមានចម្បាំងជានិច្ច (ខ៩)»**

ព្រះអង្គមានបន្ទូលថា អេសាមិនស្មោះត្រង់នៅពេលនោះ ហើយទ្រង់បាន «**ប្រព្រឹត្តបែបឆោតល្ងង់**»ទៀត។ តើព្រះបាទអេសាបានប្រព្រឹត្តបែបឆោតល្ងង់យ៉ាងម៉េចខ្លះ?

ព្រះនេត្ររបស់ព្រះយេហូវ៉ា «**ទតច្រវាត់នៅគ្រប់លើផែនដីទាំងមូល ដើម្បីសម្តែងព្រះចេស្តា**» ឲ្យអ្នកដែលនឹងពឹងលើព្រះអង្គពិត។

## ការអនុវត្តន៍តាមគំរូមិនល្អរបស់ព្រះបាទអេសា

- តើរាល់ថ្ងៃនេះ ក្នុងការសាកល្បងលមើលជំនឿដែលកើតមានក្នុងជីវិត តើខ្ញុំស្មោះត្រង់នឹងព្រះអង្គទេ ឬពឹងលើគំនិតខ្លួនទៅវិញ?

<u>ឧទាហរណ៍</u> នៅពេលដែលមេ ឬមិត្តសំលាញ់ បង្ខំ ឬបញ្ចុះបញ្ចូលឲ្យចូលរួមថ្ងៃបុណ្ណជាមួយគេ ឬផឹកស្រាជាមួយ តើខ្ញុំនឹងធ្វើអ្វី?

- នៅពេលដែលខ្ញុំខ្វាច ឬសង្ស័យ នៅពេលនោះ តើខ្ញុំនឹងស្វែងរកព្រះ ពឹងលើព្រះ ឬធ្វើតាមចិត្តរបស់ខ្លួនវិញ?

<u>ឧទាហរណ៍</u> ក្នុងពេលគ្មានទឹកប្រាក់ ខ្វះខាត តើខ្ញុំនឹងហានរកស៊ីផ្លូវបាបឬ? តើខ្ញុំនឹងហានខ្ចីប្រាក់នៅពេលដែលដឹងថា ខុស ហើយសង់គេមិនបាន?

- នៅពេលដែលខ្ញុំមិនទាន់ឃើញកាដំណោះស្រាយសម្រាប់បញ្ហាជីវិត តើខ្ញុំនឹងហាន ធ្វើខុសអំពីព្រះហឬទ័យនៃព្រះ ឬនៅតែធ្វើតាមទ្រង់?

ឧទាហរណ៍ នៅពេលគេហាមឃាត់ឥតឲ្យមកថ្វាយបង្គំព្រះ តើខ្ញុំខ្លាចមនុស្សជាជាង ព្រះឬ? ក្នុងការរកស៊ី តើខ្ញុំហានបោកគេ ផរគេ ដើម្បីរកប្រាក់ ឬខ្ញុំស្មោះត្រង់នូវចំពោះ អតិថិជនតាមព្រះហឬទ័យនៃព្រះ?

**ចិត្តរឹងរបស់ព្រះបាទអេសា**

**<u>អាន របក្សត្រ ទី២ ១៦:១០-១៤</u>**

នៅពេលដែលព្រះបាទអេសាបានឮព្រះបន្ទូលបន្ទោសពីព្រះយេហូវ៉ា ទ្រង់មិនបានបន្ទៀបខ្លួន មិនលន់តួបាបទេ លទ្ធផល អេសាបានធ្វើបាបគេខ្លះ ហើយ៥ឆ្នាំចុងក្រោយក្នុងរាជ្យរបស់ព្រះអង្គ អេសាមិនបានបម្រើព្រះយេហូវ៉ាទេ ឆ្នាំចុងក្រោយនោះបានខ្វះខ្វាយ។

**ការអនុវត្តន៍តាមគំរូមិនល្អរបស់ព្រះបាទអេសាថែមទៀត**

- នៅពេលដែលកូនព្រះមានចិត្តរឹងនូវចំពោះព្រះ បាបរបស់ពួកគេតែងតែប៉ះពាល់ដល់អ្នក ដទៃៗទៀត។
- សម្រាប់កូនរបស់ព្រះដែលប្រព្រឹត្តខុស ផលវិបាកបាបក្នុងជីវិតនៅតែមាន ទោះបើកូនទ្រង់ លន់តួបាបហើយក៏ដោយ (អេសាត្រូវមានចម្បាំងរហូត)

## រស់នៅជាមួយព្រះ ស្វែងរកព្រះ ហើយពឹងលើព្រះចុះ!

កុំឲ្យមានចិត្តរឹងនូវចំពោះព្រះអង្គ អស់អ្នកណាដែលស្វែងរកព្រះអង្គ និងពឹងផ្អែកលើទ្រង់ពិតជានឹងបានរង្វាន់។

**<u>អាន ពេត្រុស ៥:៥ខ-៨</u>**

**«ព្រះប្រឆាំងនឹងមនុស្សអួតខ្លួន តែទ្រង់ផ្ដល់ព្រះគុណដល់មនុស្សដែលដាក់ខ្លួនវិញ។ ដូច្នេះ ចូរអ្នករាល់គ្នាបន្ទាបខ្លួន នៅក្រោមព្រះហស្តដ៏ខ្លាំងពូកែរបស់ព្រះចុះ ដើម្បីឲ្យព្រះអង្គបានតម្កើងអ្នករាល់គ្នានៅវេលាកំណត់។ ចូរផ្ទេរគ្រប់ទាំងទុក្ខព្រួយរបស់អ្នករាល់គ្នាទៅលើព្រះអង្គ ដ្បិតទ្រង់យកព្រះហឫទ័យទុកដាក់នឹងអ្នករាល់គ្នា។»**

យើងត្រូវប្រុងប្រយ័ត្ន

**«ចូរដឹងខ្លួន ហើយចាំយាមចុះ ដ្បិតអារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែលទាំងគ្រហឹមដូចជាសិង្ហ ដើម្បីរកអ្នកណាម្នាក់ដែលវាអាចនឹងត្របាក់លេបបាន»។**